**សាលាកប័ត្រព័ត៌មាន ៖** កម្រងឯកសារករណីសិក្សា - និទណ្ឌភាពនៅខេត្តបន្ទាយមានជ័យ

**កាលបរិច្ឆេទ** ៖ ខែវិច្ឆិកា ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន

**ទិដ្ឋភាពរួម** ៖ ករណីដែលថាបុរសម្នាក់ប្រឈមនឹងបញ្ហាផ្លូវច្បាប់ ដោយសារតែបំពេញតួនាទីរបស់ខ្លួន និងការពារសិទ្ធិរបស់ស្ត្រីវ័យក្មេងម្នាក់ដែលជាជនរងគ្រោះនៃអំពើបៀតបៀនកេរ្តិ៍ខ្មាស់បង្ហាញអំពីការរំលោភបំពាននៃប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) ដែលមប្រើឲ្យតែការពារផលប្រយោជន៍របស់អ្នកមានអំណាច និងអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាជាងការផ្តល់យុត្តិធម៌ និងដំណោះស្រាយសម្រាប់ជនរងគ្រោះដែលទៅពឹងតុលាការ។ បច្ចុប្បន្ននេះ ប្រព័ន្ធតុលាការនៃប្រទេសកម្ពុជាអនុវត្តផ្ទុយពីកម្មវត្ថុរបស់ខ្លួន។

## សេចក្តីផ្តើម

សាលាកប័ត្រព័ត៌មាននេះបង្ហាញនូវទិដ្ឋភាពរួមនៃបញ្ហានិទណ្ឌភាព ដែលរីករាលដាលគ្រប់ទីកន្លែងនៃប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ សាលាកប័ត្រព័ត៌មាននេះផ្តោតលើករណីសិក្សាមួយដែលកើតមាននៅក្នុងខេត្តបន្ទាយមានជ័យ និងវិភាគទៅលើបច្ច័យអវិជ្ជមាននានាដោយសារអំពើពុករលួយក្នុងការអនុវត្តន៍ច្បាប់។ សាលាកប័ត្រព័ត៌មាននេះចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## សាវតានៃករណី

នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ លោក ស៊ុំ ច័ន្ទគា អ្នកសម្របសម្រួលប្រចាំខេត្តបន្ទាយមានជ័យរបស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (“អាដហុក”) ត្រូវបានព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យកោះហៅឲ្យចូលខ្លួនទៅបំភ្លឺនៅការិយាល័យព្រះរាជអាជ្ញា បន្ទាប់ពីទទួលបណ្តឹងមួយពីលោក អ៊ំ សុជាតិ ដែលជាប្រធានសាខាខេត្តបន្ទាយមានជ័យរបស់មជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា (“ស៊ីម៉ាក់”) និងជាមន្ត្រីសម្របសម្រួលរួមរវាងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ និងកម្មវិធីកម្ចាត់មីនស៊ីម៉ាក់។ ដីកាកោះហៅលោក ស៊ុំ ច័ន្ទគា ធ្វើឡើងបន្ទាប់ពីកិច្ចអន្តរាគមន៍របស់សមាគមអាដហុកឆ្លើយតបទៅនឹងបណ្តឹងរបស់ស្ត្រីបម្រើអាយុ២៥ ឆ្នាំម្នាក់ ដោយចោទប្រកាន់លើលោក អ៊ំ សុជាតិ និងបុរសម្នាក់ទៀតឈ្មោះ ផង់ ពិសិដ្ឋ ពីបទបៀតបៀនកេរ្តិ៍ខ្មាស់ បង្ខិតបង្ខំរួមភេទ និងប្រើប្រាស់អំពើហិង្សាលើស្ត្រី ដែលបានកើតឡើងកាលពីថ្ងៃទី០៤ និង ០៩ ខែវិច្ឆិកា ឆ្នាំ២០១១។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ លោក អ៊ំ សុជាតិ បានដាក់ពាក្យបណ្តឹងចំពោះលោក ស៊ុំ ច័ន្ទគា បន្ទាប់ពីគាត់បានជួយជ្រោមជ្រែងស្ត្រីបម្រើឲ្យដាក់ពាក្យបណ្តឹងពីបទបៀតបៀនកេរ្តិ៍ខ្មាស់ចំពោះបុរសទាំងពីរនាក់ខាងលើ និងបានជម្រុញឲ្យសមត្ថកិច្ច និង ការិយាល័យព្រះរាជអាជ្ញា ចាត់វិធានការ និងស៊ើបអង្កេតលើករណីនេះ។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ តុលាការបានសាកសួរជាបឋមលើរូបលោក ស៊ុំ ច័ន្ទគា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទបរិហារបង្កាច់កេរ្តិ៍ យោងតាមមាត្រា៣១១ នៃក្រមព្រហ្មទណ្ឌ តែទោះជាយ៉ាងនេះក្តី តុលាការបន្តសាកសួរគាត់ទាក់ទិននឹងការបង្ខិតបង្ខំ ឬញុះញង់ស្ត្រីបម្រើឲ្យដាក់ពាក្យបណ្តឹងបៀតបៀនកេរ្តិ៍ខ្មាស់ប្រឆាំងនឹងលោក អ៊ំ សុជាតិ ។ មកទល់ពេលនេះការិយាល័យព្រះរាជអាជ្ញានៅមិនទាន់ចោទប្រកាន់ ហើយក៏មិនទាន់មានតម្រុយថានឹងមានការចោទប្រកាន់ណាមួយលើរូបលោក ស៊ុំ ច័ន្ទគា នៅឡើយទេ។

## យោងតាមខ្លឹមសារច្បាប់

យោងតាមមាត្រា៣១១ នៃក្រមព្រហ្មទណ្ឌ បុគ្គលណាម្នាក់អាចមានពិរុទ្ធពីបទបរិហារបង្កាច់កេរ្តិ៍ ប្រសិនបើគាត់ *“ប្តឹងបរិហារអំពីអំពើដែលគេដឹងថាមិនពិត ហើយដែលនាំឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬ វិន័យ កាលបើការប្តឹងបរិហារនេះត្រូវបានផ្ញើទៅដល់ ...”* បន្ថែមលើអ្វីដែលលោក ស៊ុំ ច័ន្ទគា បានធ្វើនោះគឺការផ្តល់ពិគ្រោះផ្នែកច្បាប់ ហើយហេតុការណ៍ដែលត្រូវបានលើកឡើងយ៉ាងណាក៏ដែលនាំឲ្យមានការចោទប្រកាន់លើរូបគាត់ពុំត្រឹមត្រូវទេ។ បើលោក ស៊ុំ ច័ន្ទគា ដឹងថាការពិតនោះមិនត្រឹមត្រូវ ការពិតត្រូវតែមិនត្រឹមត្រូវតាំងពីដំបូងមកម្លេះ។ មានតែតុលាការទេដែលមានសមត្ថកិច្ចបញ្ជាក់ពីបញ្ហានេះ។ តុលាការត្រូវដោះស្រាយបណ្តឹងរបស់ស្ត្រីបម្រើ មុនពេលចាត់ការលើបណ្តឹងតបរបស់លោក អ៊ំ សុជាតិ។ ប្រសិនបើលោក ស៊ុំ ច័ន្ទគា ត្រូវបានរកឃើញថាមានពិរុទ្ធភាព មែននោះ បណ្តឹងបរិហារបង្កាច់កេរ្តិ៍ច្បាស់ណាស់ថាពិតជាបណ្តឹងពុំត្រឹមត្រូវដែលនាំឲ្យខ្ជះខ្ជាយពេលវេលារបស់តុលាការ និងជាការបរាជ័យក្នុងការស្វែងរកយុត្តិធម៌។ ម.ស.ម.ក សន្មត់ជាមុនថានឹងគ្មានការចោទប្រកាន់ពីបទញុះញង់ ពីព្រោះថាមានតែការញុះញង់

ឲ្យប្រព្រឹត្តបទល្មើស ឬបង្កចលាចលទៅដែលជាបទល្មើស។ ជាការពិត យោងតាមមាត្រា៥២៧ នៃក្រមព្រហ្មទណ្ឌ អំពើគម្រាមកំហែងសម្លុតដើម្បីញុះញង់ជនរងគ្រោះកុំឲ្យដាក់ពាក្យបណ្តឹងជាបទល្មើសព្រហ្មទណ្ឌ។

សមាគមអាដហុកមិនបានបំពានច្បាប់ដោយគ្រាន់តែផ្តល់ជំនួយផ្នែកច្បាប់ដល់ស្ត្រីបម្រើមុនពេលដែលនាងសម្រេចដាក់ពាក្យបណ្តឹងណាមួយនោះ។ ជាក់ស្តែង យោងតាមមាត្រា១ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩៨ ចែងថា៖ *"បុគ្គលគ្រប់រូបមានសិទ្ធិ ដោយឡែកក្តី និងរួមគ្នាក្តី ដើម្បីលើកកម្ពស់ និងតស៊ូសម្រាប់កិច្ច ការពារ និងការទទួលស្គាល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងក្នុងថ្នាក់ជាតិ និងអន្តរជាតិ"*។ លោក សុំ ច័ន្ទគា គ្រាន់តែបំពេញតួនាទីរបស់គាត់ ហើយគាត់ត្រូវបានការពារ និងគាំទ្រតាមរយៈគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ។

**ការបន្តនិទណ្ឌភាពនៅកម្ពុជា**

អាជ្ញាធរកម្ពុជាបន្តដាក់កំហិតហួសហេតុលើសកម្មភាពអ្នកការពារសិទ្ធិមនុស្សតាមរយៈការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ជំនួសឲ្យការការពារប្រជាពលរដ្ឋរបស់ខ្លួន និងការស៊ើបអង្កេតការចោទប្រកាន់លើករណីរំលោភសិទ្ធិមនុស្ស – សមាគមអាដហុករាយការណ៍ថានេះជាលើកទីបីហើយក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ដែលបុគ្គលិករបស់ខ្លួនត្រូវបានគម្រាមកំហែងតាមរយៈការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ឬ បទញុះញង់ បន្ទាប់ពីពួកគេបានធ្វើសកម្មភាពតស៊ូមតិ និងអប់រំអំពីសិទ្ធិមនុស្ស។ អាទិភាពរបស់រដ្ឋនៅក្នុងករណីបែបនេះជាការគាបសង្កត់យ៉ាងច្បាស់ទៅលើសេរីភាពខាងការបញ្ចេញការពិត ឬមតិយោបល់ ដែលអាចអន្តរាយដល់ផលប្រយោជន៍របស់ខ្លួន ឬរបស់ស្ថាប័នក្រោមឱវាទផ្សេងទៀត។ ដើម្បីរក្សាបណ្តាញដែលខ្លួនបានតែងតាំងនៅគ្រប់ទីកន្លែងរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរមូលដ្ឋានដែលជាបរិវារយរបស់ខ្លួនចាំបាច់ត្រូវរក្សាអំណាចឲ្យនៅក្នុងដៃខ្លួន។ ជាក់ស្តែង ការចោទប្រកាន់ដែលថាប្អូនប្រុសនាយករដ្ឋមន្ត្រី ឈ្មោះ ហ៊ុន សាន បានសរសេរលិខិតមួយស្នើសុំឲ្យព្រះរាជអាជ្ញាបញ្ឈប់ការស៊ើបអង្កេតនៅក្នុងសំណុំរឿងរបស់លោក អ៊ំ សុជាតិ។ អាជ្ញាធរត្រូវបានគេចោទប្រកាន់ថាមិនបានចាត់វិធានការដើម្បីស៊ើបអង្កេតលើបណ្តឹងរបស់ស្ត្រីបម្រើនោះទេ។

បញ្ហាចម្បងក្នុងករណីបែបនេះគឺថាអាជ្ញាធរលើកទឹកចិត្តអំពើនិទណ្ឌភាព ដោយពុំបានពិចារណាទៅលើសិទ្ធិរបស់ជនរងគ្រោះ និងអ្នកទាំងឡាយណាដែលព្យាយាមជួយជ្រោមជ្រែងពួកគាត់។ ឥឡូវនេះអ្នកតំណាងអាជ្ញាធរនៅមូលដ្ឋានដែលមានទំនាក់ទំនងស្និទ្ធ អ្នកជំនួញ ឬរដ្ឋមន្ត្រីយល់ថាប្រសិនគាត់ចង់ប្រព្រឹត្តអំពើរំលោភផ្លូវភេទ ឬអំពើបៀតបៀនកេរ្តិ៍ខ្មាសលើស្ត្រីវ័យក្មេងគាត់អាច ធ្វើបានដោយគ្មានទោស។ ជាក់ស្តែង យោងតាមសមាគមអាដហុក ស្ត្រីវ័យក្មេងបានចោទប្រកាន់អ្នកបំពានមកលើគាត់ថាបានគម្រាមកំហែងតាមទូរស័ព្ទ និងប្រាប់នាងថា *"នាងគ្មានអំណាចអ្វីមកតតាំងនឹងគាត់ទេ"*។ នៅក្នុងករណីបែបនេះ ជនរងគ្រោះនឹងមានការភិតភ័យជាខ្លាំងក្នុងការនិយាយស្តីពេលជួបប្រទះនឹងអ្នកគម្រាមកំហែងនៃអំពើបៀតបៀនកេរ្តិ៍ខ្មាស ដោយគាត់ត្រូវប្តូរលេខទូរស័ព្ទ និងបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនក្រោយពីទទួលទូរស័ព្ទរំលោភបំពានបែបនេះ និងដឹងថាប្រព័ន្ធតុលាការនឹងមិនអាចការពារពួកគាត់បានទេ ឬ ជាការត្រៀមប្រើប្រាស់ប្រព័ន្ធតុលាការប្រឆាំងនឹងពួកគាត់ និងប៉ះពាល់អាយុជីវិតប្រជាពលរដ្ឋខ្មែរស្លូតត្រង់ជាច្រើននាក់ទៀត។ មិនតែប៉ុណ្ណោះ បុរស និងស្ត្រីដ៏អង់អាចក្លាហានទាំងអស់ដែលប្តេជ្ញាការពារសិទ្ធិមនុស្សនឹងគិតទ្វេដងមុននឹងចូលទៅពាក់ព័ន្ធ ជាមួយករណីបែបនេះជាថ្មីទៀតនាពេលអនាគត ហើយនេះជាគន្លឹះយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។

**សេចក្តីសន្និដ្ឋាន**

ករណីសិក្សានេះគួសបញ្ជាក់ពីរឿងអាស្រូវជាច្រើនដែលពិបាកដោះស្រាយដូចជា៖ ទំហំនៃការងាយរំលោភបំពាន និងរំលោភបំពានរួចហើយនៅក្នុងប្រព័ន្ធតុលាការកម្ពុជាកាន់តែរីករាលដាលធំទៅៗ មានការបង្កើតអង្គហេតុតបដែលយល់ឃើញថាត្រឹមត្រូវធ្វើឡើង ដើម្បីបំបិទមាត់ និងដាក់ទណ្ឌកម្មលើប្រជាពលរដ្ឋ និងអ្នកការពារសិទ្ធិមនុស្សដែលទន់ខ្សោយ និងងាយរងគ្រោះដែលលើកឡើងពីទង្វើខុសច្បាប់ ជាជាងការពារ និងលើកទឹកចិត្តពួកឲ្យធ្វើដូច្នោះ ហើយកម្រិតនៃនិទណ្ឌភាពមានអាទិភាពទោះបីស្ថិតក្នុងស្ថានភាពយ៉ាងណាក៏ដោយឲ្យតែគាំទ្រដល់អ្នកមានអំណាច និងអ្នកមានទំនាក់ទំនងជិតស្និទ្ធដែលពួកគេគិតថាពួកគេរឹតតែមានអំណាចធ្វើអ្វីដែល ខ្លួនចង់ធ្វើ និងវិសាលភាពនៃអំណាចតុលាការដែលតែងតែនៅចាំការពារផលប្រយោជន៍របស់ពួកគេ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ រីរៈ តាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៤០ ៤០ ៥១ ឬតាមរយៈអ៊ីមែល ouvirak@cchrcambodia.org ឬលោក រ៉ូប៊ឺត ហ្វីន តាមរយៈលេខ (៨៥៥) ៧៨ ៨០ ៩៩ ៦០ ឬតាមរយៈអ៊ីមែល robert.finch@cchrcambodia.org ។